**Program:** ឃាតកម្មមុនចូលគេង

**Topic:** William Bonin ( ឃាតកដែលសម្លាប់តែមនុស្សប្រុស )

**Categories:** Crime Investigation

**Check: Done**

**Content by:** Prey Reung



---

**Hook**

សូមស្វាគមន៍មកកាន់CamID Podcast!

"បើសិនជាអ្នកចង់សម្លាប់នណាម្នាក់ អ្នកគួរតែរៀបចំគម្រោងការ ទុកមុន និងរកកន្លែងណាដែលអាចលាក់សាកសពបាន មុនពេលដែលអ្នកជ្រើសរើសជនរងគ្រោះ" នេះគឺជាសម្ដីរបស់ឃាតក ជនជាតិអាមេរិកម្នាក់ បានប្រាប់ទៅកាន់អ្នកដំណើរម្នាក់ ដែលគេបានទុកជីវិតអោយ។

**Intro**

រឿងរ៉ាវរបស់ឃាតកម្នាក់ ដែលបានសម្លាប់មនុស្សប្រុសអស់២១នាក់ ដែលសុទ្ធសឹងតែជាក្មេងប្រុសទាំងអស់។ ឃាតកម្នាក់នេះត្រូវបានគេស្គាល់ថាជាឃាតករោគចិត្តដែលសាហាវឃោឃៅ ដល់ថ្នាក់រំលោភបំពានក្មេងប្រុស និងធ្វើទារុណកម្មមុនសម្លាប់ទៀតផង។

អ្វីដែលគួរអោយខ្លាចនោះ គឺគេតែងតែធ្វើសកម្មភាពសម្លាប់នៅលើផ្លូវជាតិតែប៉ុណ្ណោះ ឃាតកម្នាក់នេះ ត្រូវបានគេអោយរហ័សនាមថា The Freeway Killer។

អ្នកណាដែលដើរនៅលើផ្លូវតែម្នាក់នោះ ប្រាកដជាក្លាយចំណីរបស់ឃាតកខ្លាកំណាចម្នាក់នេះហើយ ព្រោះគេមិនខ្វល់ថាអ្នកជានណានោះទេ។

ថ្ងៃនេះព្រៃរឿងនឹងលើកយករឿងរ៉ាវនេះមកបកស្រាយ តែមុននិងចូលទៅដល់សាច់រឿង មកដឹងពីប្រវត្តិខ្លះរបស់ឃាតកជាមុនសិន។

**Body**

រឿងរ៉ាវនេះ នឹងនាំអ្នកទាំងអស់គ្នា អោយមកស្គាល់ឃាតកម្នាក់ឈ្មោះ William Bonin។ Bonin កើតនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៤៧ នៅក្រុង Willimantic រដ្ឋConnecticut នៃប្រទេសសហរដ្ឋអាមេរិក។

Bonin ជាកូនទី២ នៃបងប្អូន៣នាក់។ ឪពុករបស់គេគឺជាជនប្រមឹក និងអ្នកដែលញៀនល្បែងម្នាក់ ដោយតែងតែធ្វើបាប និងប្រើអំពើហិង្សាទៅលើប្រពន្ធកូនជានិច្ច។

ដោយសារតែឪពុករបស់គេ មានឥរិយាបថបែបនេះទើប Bonin និងបងប្អូនគាត់ទាំងប៉ុន្មានអ្នកទៀត តែងតែទៅនៅជាមួយតាយាយរបស់ពួកគេជារឿយៗ។ ពួកគេជាក្មេងដែលខ្វាក់ការថែទាំពីឪពុកម្តាយ និងរស់ដោយសារតែអ្នកជិតខាងតែប៉ុណ្ណោះ។

នៅពេលដែលBoninអាយុ៦ឆ្នាំ Boninត្រូវបានម្តាយរបស់គេ បញ្ជូនអោយទៅរស់នៅក្នុងមណ្ឌលកុមារកំព្រាមួយ រហូតដល់គេមានអាយុ៩ឆ្នាំ។

គួរបញ្ជាក់ផងដែរថា នៅក្នុងមណ្ឌលកំព្រានេះ គឺគេត្រូវបានគេធ្វើបាប និងទទួលរងការរំលោភបំពានអស់ជាច្រើនលើកមកហើយ។

មួយឆ្នាំក្រោយបន្ទាប់ពីBoninចេញពីមណ្ឌលកុមារកំព្រា Boninត្រូវបានប៉ូលិសចាប់ខ្លួនជាលើកដំបូងក្នុងករណីលួចស្លាកលេខឡាន និងបទឧក្រិដ្ឋផ្សេងៗ ដែលគ្រានោះ Bonin ត្រូវគេបញ្ជូនទៅឃុំឃាំងនៅមណ្ឌលកែប្រែអស់មួយរយះ។

បន្ទាប់ពីចេញពីមណ្ឌលកែប្រែវិញ ក្នុងវ័យជំទង់ Bonin ចាប់ផ្តើមចេះរំលោភបំពានទៅលើកុមារបាត់ទៅហើយ ដែលក្នុងនោះរួមមានប្អូនរបស់គេ និងអ្នកជិតខាងក្មេងៗនៅទីនោះ។

នៅឆ្នាំ១៩៦៥ Boninបានបញ្ចប់ការសិក្សានៅវិទ្យាល័យ រួចBoninបានភ្ជាប់ពាក្យ ព្រោះម្តាយរបស់គេជឿជាក់ថា ការធ្វើបែបនេះប្រាកដជាអាចបញ្ឈប់Boninពីការស្រលាញ់ភេទដូចគ្នា។

នៅឆ្នាំដដែរ Boninបានចូលចម្រើកងទ័ពអាកាស របស់សហរដ្ឋអាមេរិក ដើម្បីធ្វើសង្គ្រាមជាមួយវៀតណាមនៅគ្រានោះ។

អ្វីដែរគួរអោយកោតសរសើរចំពោះBoninនោះ គឺថាBoninបានប្រថុយប្រថានជីវិតរបស់ខ្លួន ដើម្បីជួយសង្គ្រោះទាហានជាច្រើននាក់ ក៏ប៉ុន្តែក្នុងពេលតែមួយBoninក៏បានរំលោភទាហានពីនាក់ដែរ តែករណីនេះមិនត្រូវបានគេរាយការណ៍នោះទេ។

យ៉ាងណា ក្រោយមក នៅឆ្នាំ១៩៦៨ Bonin ក៏បានចាកចេញពីការធ្វើទាហាន ដោយក្តីកិត្តិយស និងបន្សល់មេដាយមាស ពីការជួយសង្គ្រោះមិត្តទាហានរបស់គេទៀត។

រួចមក រូបគេក៏ទៅរស់នៅជាមួយម្តាយរបស់គេនៅឯរដ្ឋ Connecticut វិញ ក៏ប៉ុន្តែក្រោយមកទៀត គេក៏ប្តូរទៅនៅរដ្ឋ California វិញ។

មកដល់Californiaមិនបានប៉ុន្មានផង ពោលគឺ តែ១ខែសោះ Bonin ពេលនោះមានអាយុ២៤ឆ្នាំ បានចាប់ជំរិត និងរំលោភបំពានផ្លូវភេទ យុវជន៥នាក់។

១ឆ្នាំក្រោយមក Bonin ត្រូវបានប៉ូលិសចាប់ខ្លួន ពីបទឧក្រិដខាងលើនេះ ហើយគេបានបញ្ជូន Boninទៅព្យាបាលនៅមន្ទីពេទ្យវិកលចរិកដែលធ្វើឲ្យគេដើរបំពានផ្លូវភេទអ្នកដទៃ ក៏ប៉ុន្តែ Bonin មិនអាចព្យាបាលបាននោះទេ រួចហើយក៏ត្រូវបានបញ្ជូនទៅដាក់គុកចំនួនប្រាំឆ្នាំ។

ទីបំផុត Bonin ក៏ត្រូវបានគេដោះលែង អោយមានសេរីភាពវិញ ក្រោយពីគ្រូពេទ្យ បានបញ្ជាក់ថាគេជាសះស្បើយពីជម្ងឺនេះហើយ។ តាមការពិត Bonin មិនបានជាពីជម្ងឺនោះទេ ពោលគឺ ១៦ ខែក្រោយពេលចេញពីគុក Bonin ត្រូវបានប៉ូលិសចាប់ខ្លួនម្តងទៀត ពីបទចាប់រំលោភក្មេងប្រុសម្នាក់អាយុ១៤ឆ្នាំ ឈ្មោះថា David McVicker និងបទប៉ុនប៉ងចាប់ជំរិតក្មេងជំទង់ម្នាក់ទៀត ដែលទោសនេះអាចនឹងជាប់គុគពី១ឆ្នាំទៅ១៥ឯនោះ នៅរដ្ឋCalifornia។

ក៏ប៉ុន្តែ៤ឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៨ Bonin ត្រូវបានគេដោះលែង អោយមានសេរីភាពម្តងទៀត រួចក៏បានទៅរស់នៅឯរដ្ឋ Downey។

ការចេញពីគុកលើកនេះ Boninមិនខ្លាចជាប់គុកម្តងទៀតឡើយ ផ្ទុយទៅវិញរូបគេ ថែមទាំងស្បថថា មិនអោយប៉ូលិសចាប់បានម្តងទៀតនោះឡើយ។

សំណួរសួរថា តើBoninមានគម្រោងធ្វើអីបន្ទាប់ពី គេបានស្បថរួចមកហើយនោះ?

លុះក្រោយមក Boninក៏បានធ្វើការជាអ្នកបើកឡានដឹកទំនិញធំៗ និងចេះណាត់ជួបស្រីៗទៀតផង។

ពេលនេះហើយBonin ដែលជាឃាតកបើកឡាន នឹងសម្លឹងមើលឃើញជនរងគ្រោះ នៅតាមផ្លូវដែលស្ងាត់ជ្រងំ។

គួរបញ្ជាក់ផងដែរថា នៅពេលដែលBoninធ្វើការនៅរដ្ឋDowney Boninចាប់ផ្តើមចេះរាប់អានអ្នកជិតខាង ហើយអ្នកដែលជិតស្និតជាមួយគេ ឈ្មោះថាEverett Fraser។

Bonin និងFraserក៏មានពីធីជប់លាងមួយនៅApartmentរបស់Fraser អំឡុងពេលនោះBoninក៏បានស្គាល់មិត្តចំណូលថ្មី២នាក់ទៀត ដែលម្នាក់ជាកម្មកររោងចក្រ និងជាអ្នកលេងសៀកម្នាក់ ឈ្មោះថាVernon Butts ហើយនិងម្នាក់ទៀតមកពីរដ្ឋTexas មានឈ្មោះថាGregory Matthew Miley។

ពួកគេទាំងអស់នេះហើយ ដែលផ្សំគំនិតគ្នាជាមួយBonin សម្លាប់ និងរំលោភមនុស្សប្រុសអស់២១នាក់ ត្រឹមរយះពេលតែ១០ខែប៉ុណ្ណោះ គឺរាប់ចាប់តាំងពីថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៩ ដល់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៨០។

លើកលែងតែ Fraserតែប៉ុណ្ណោះ ដែលមិនមានវត្តមាននៅក្នុងហេតុការណ៍ទាំងនេះ

ជនរងគ្រោះដំបូងរបស់Bonin គឺមានអាយុ១៣ឆ្នាំ មានឈ្មោះថា Thomas Glen Lundgren គឺជាអ្នកដំណើរតាមផ្លូវម្នាក់ ដែលត្រូវគេបានប្រទះឃើញលើកចុងក្រោយ នៅពេលដែលThomasចេញពីផ្ទះ មុនពេលដែលត្រូវបានBonin និងVernonចាប់ជំរិតនិងសម្លាប់។

សាកសពរបស់Thomasត្រូវបានគេរកឃើញថា ដាច់អវយវះភេទ និងត្រូវគេវៃឡើងខ្ទិចមុខ។

ក្រោយមកBoninត្រូវបានគេចាប់ខ្លួន ពីបទបំពានក្មេងប្រុសម្នាក់អាយុ១៧ឆ្នាំទៅវិញ ក៏ប៉ុន្តែ Boninត្រូវបានដោះលែងវិញ ដោយសារតែមានបញ្ហាបច្ចេកទេសផ្នែករដ្ឋបាល។

បន្ទាប់ពីគេត្រូវបានដោះលែងបានពីរខែ Bonin និងដៃគូរបស់គេ Buttsបានចាប់បំពាន និងសម្លាប់ក្មេងប្រុសអាយុ១៧ឆ្នាំម្នាក់ទៀត ឈ្មោះថាMark Shelton។

Markត្រូវបានBonin និងButts បំពានយ៉ាងសាហាវព្រៃផ្សៃ និងយកខ្សែភ្លើងមកធក់រហូតដល់ស្លាប់ ហើយសាកសពរបស់គេ ត្រូវបានបោះចោលនៅតំបន់San Bernardinoយ៉ាងគួរអោយសង្វេគ។

ក្រោយពី Mark ស្លាប់បានមួយថ្ងៃ Bonin និងButts បានសម្លាប់អ្នកដំណើរអាយុ១៧ម្នាក់ទៀតឈ្មោះMarkus Crabs នៅឯផ្ទះរបស់ជនរងគ្រោះតែម្តង រួចហើយ ក៏បោះចោលសាកសពនោះនៅតាមដងផ្លូវ Malibu។

ពីរបីថ្ងៃក្រោយមក ពួកគេទាំងពីរ បានចាប់ និងសម្លាប់ក្មេងប្រុសម្នាក់ទៀត អាយុ១៥ឆ្នាំ ឈ្មោះថា Donald Ray Hyden។

សាកសពរបស់Hydenត្រូវបានគេរកឃើញនៅតាមដងផ្លូវVentura ហើយត្រូវបានឃាតកទាំងពីរ បោកក្បាលនឹងជញ្ជាំងដែលធ្វើឲ្យមានស្នាមរបួស នៅលើលលាដ៏ក្បាល និងវាយរហូតដល់ស្លាប់ រីឯកសាកសពរបស់Hyden ត្រូវបានចាក់អស់ជាច្រើនកាំបិត ផងដែរ។

រំលងបានពីរសប្តាហ៍សោះ Bonin និងButtsដដែរ បានចាប់ក្មេងប្រុសម្នាក់ទៀត ដាក់នៅក្នុងឡានរបស់ពួកគេ ក្មេងប្រុសម្នាក់នោះ ឈ្មោះថាDavid Murillo អាយុ១៧ឆ្នាំ ដែលពេលនោះ Davidកំពុងតែធ្វើដំណើរទៅរោងភាពយន្ត។ Davidត្រូវបានពួកគេបំពាន និងវាយរហូតដល់ស្លាប់តែម្តង។

នេះគ្រាន់ តែជាការរៀបរាប់ត្រួសៗតែប៉ុណ្ណោះ ហើយនៅមានជនរងគ្រោះបន្តបន្ទាប់ទៀតដែលត្រូវបានBonin និងគ្នីគ្នារបស់គេបានសម្លាប់ តែព្រៀងសូមមិនយកមកស្រាយទេ ដែលជនរងគ្រោះទាំងអស់នោះ សុទ្ធតែត្រូវបានគេសម្លាប់ស្រដៀងៗគ្នា គ្រាន់តែកន្លែងខុសៗគ្នា ហើយពេលវេលា ដែលពួកគេសម្លាប់គឺរំលងគ្នាមិនដល់មួយខែនោះទេ។

ករណីឃាតកម្មរបស់Boninគឺភាគច្រើននៅតាមផ្លូវ ហើយសុទ្ធសឹង តែជាអ្នកដំណើរដែលសុំឡានគេធ្វើដំណើរ។

តែទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមជនរងគ្រោះទាំងអស់ គឺមានអ្នកដំណើរម្នាក់ ដែលធ្លាប់ជាអ្នករួចផុតពីការសម្លាប់របស់Bonin ក៏ប៉ុន្តែ អ្វីដែលនឹកស្មានមិនដល់នោះគឺថា គេក៏ក្លាយទៅជាដៃគូរបស់Boninទៅវិញ

អ្នកដំណើរនោះឈ្មោះថា William Pugh អាយុតែ១៧ឆ្នាំតែប៉ុណ្ណោះ។

ដំណើររឿងគឺ គ្រាមួយBoninបានជួយជូនWilliamទៅផ្ទះ Williamក៏យល់ព្រម។

ក្នុងឡានតែពីរអ្នក Boninក៏បានសួរWilliamថា តើWilliamចង់រួមភេទជាមួយគេឬអត់?

រំពេចនោះWilliamក៏និយាយបដិសេធទាំងអារម្មណ៍ភ័យផង និងញ័រផង
និងថែមទាំងចង់រត់ចេញពីលើឡាន ក៏ប៉ុន្តែ Williamបានជាប់នឹងខ្សែក្រវ៉ាត់ឡាន
ដូច្នេះWilliamមិនអាចគេចទៅណានោះទេ។

ប៉ុន្មាននាទីក្រោយមក Boninក៏បានបន្តថារូបគេឥឡូវពេញចិត្តនឹងការបំពាន
និងសម្លាប់អ្នកដំណើរប្រុសៗណាស់

ការនិយាយសារភាពបែបនេះរឹតតែធ្វើអោយWilliamកាន់ភ័យឡើងៗ។

Boninមិនបានបំពាន ឬក៏ធ្វើបាបWilliamនោះទេ ហើយថែមទាំងប្រាប់Williamថា
"បើសិនជាអ្នកចង់សម្លាប់នណាម្នាក់ អ្នកគួរតែរៀបចំគម្រោងការទុកមុន
និងរកកន្លែងណាដែលអាចលាក់សាកសពបាន មុនពេលដែលអ្នកជ្រើសរើសជនរងគ្រោះ"។

គ្រានោះ Williamបានត្រឡប់ទៅផ្ទះយ៉ាងសុវត្ថិភាព។ ហើយក្រោយមក
Williamក៏រួមដៃគ្នាជាមួយBoninក្នុងការសម្លាប់ជនរងគ្រោះបន្តបន្ទាប់ទៀតទៅវិញ។

នៅមានអ្នកដំណើរម្នាក់ទៀត ដែលក្លាយជាដៃគូររបស់Boninដែរ ឈ្មោះថាJames Munro អាយុ១៨ ឆ្នាំ
ដោយJamesត្រូវបានបណ្តេញចេញពីគ្រួសារ និងគ្មានការងារធ្វើឡើយ ហើយក៏ទៅជួបនឹងBonin។

Boninបានចែករំលែកកន្លែងស្នាក់នៅដល់James ជាមួយគ្នា និងថែមទាំងផ្តល់ការងារ
ជាអ្នកដឹកជញ្ជូនទៀតផង។

ពួកគេទាំងពីថែមទាំង ធ្លាប់មានទំនាក់ទំនងស្នេហាភេទដូចគ្នាជាមួយគ្នាផងដែរ។

ការផ្តល់ភាពកក់ក្តៅពីBoninបែបនេះ ក៏បានជំរុញអោយJames
ក្លាយទៅជាឃាតកររួមដៃគ្នាជាមួយBonin។

នៅក្នុងក្តីស៊ើបអង្កេតអំពីឃាតកម្ម The Freeway Killer ខាងលើនេះ គឺWilliam ត្រូវបានប៉ូលិសចាប់ខ្លួន
និងសាកសួរមុនគេ។

William បានប្រាប់ប៉ូលិសថាBoninប្រហែលជាឃាតក។ ក្រោយពីទទួលបានដំណឹងនេះ Boninក៏ក្លាយជាជនសង្ស័យសំខាន់របស់ប៉ូលិស ព្រោះប៉ូលិស បានដឹងពីអតីតកាលរបស់Bonin ថាធ្លាប់ជាមនុស្សចាប់រំលោភក្មេងប្រុសពីមុនមក។

អ្នកស៊ើបការម្នាក់ឈ្មោះថាJohn ក៏បានដាក់ក្រុមស៊ើបអង្កេតមួយ ដើម្បីឃ្លាំមើលសកម្មភាពរបស់Boninផងដែរនាគ្រានោះ។

ចៃដន្យអំឡុងពេលស៊ើបអង្កេត ពោលគឺនៅថ្ងៃទី២ ខែមុថិនា ឆ្នាំ១៩៨០ Bonin និងJames បានចាប់ក្មេងប្រុសទៀត ដាក់ក្នុងឡានរបស់ពួកគេ ក្មេងនោះមានអាយុ១៥ ឈ្មោះថា Steven Jay Well។

រួចហើយពួកគេក៏សម្លាប់ក្មេងនោះម្នាក់ទៀត។

ទីបំផុតនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៨០ ការប្រព្រឹត្តអំពើដ៏ព្រៃផ្សៃរបស់Bonin ក៏ត្រូវបានបញ្ចប់ ពោលគឺក្រុមអ្នកឃ្លាំមើលរបស់ប៉ូលិស ជិះឡានតាមBonin រហូតដល់ចំណតមួយ នៅសួនសារធារណៈមួយ ដោយពេលនោះBoninកំពុងតែចាំចាប់ជនរងគ្រោះម្នាក់ទៀត។

ក្រោយមកទៀត អ្នកដែលផ្សំគំនិតជាមួយគេ ទាំងប៉ុន្មានត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់។

ស្របពេលដែលBoninកំពុងជាប់ការឃុំឃាំង Boninក៏បានសារភាពថា រូបគេបានសម្លាប់ក្មេងប្រុសអស់២១នាក់ ជាមួយដៃគូរបស់គេម្នាក់ទៀតគឺ Vernon Butts នោះឯង។

ប៉ូលិសក៏សង្ស័យថា ចំនួននៃអ្នកស្លាប់ប្រហែលជាមានលើសពីការសារភាពរបស់Boninទៅទៀត។

កំឡុងពេលដែលតុលារស៊ើបរឿងក្តី ដៃគូរបស់គេ ទាំងប៉ុន្មានមានដូចជា Butts, William , James និងMiley ព្រមសារភាព ប្រាប់តុលាការ ទាំងអស់ពីសេចក្តីលំអិតនៃឃាតកម្មមួយនេះ និងសារភាពប្រាប់ចំនួនជនរងគ្រោះ ដែលពួកគេបានរួមដៃជាមួយBoninសម្លាប់ទៅកាន់ប៉ូលិសរៀងៗខ្លួន។

ជាចុងក្រោយBoninត្រូវបានតុលាការកាត់ទោសប្រហារជីវិតការចាក់ថ្នាំសម្លាប់ ពីបទសម្លាប់មនុស្ស១២នាក់ នេះគឺចំនួន ដែលប៉ុលិសរកឃើញសាកសព។

រីឯButts វិញ ក៏មានទោសធ្ងន់ដែរ ក៏ប៉ុន្តែរូបគេ បានសម្លាប់ខ្លួនដោយចងកខ្លួនឯង មុនពេលដែលតុលារកាត់ទោសបាត់ទៅហើយ។

ហើយអ្នកផ្សេងទៀតគឺមានទោសជាប់គុកចាប់ពី៥ ទៅ២៥ឆ្នាំ ដោយអាស្រ័យទៅលើការសម្លាប់របស់ពួកគេរៀងៗខ្លួន។

**Ending**

តាមរយៈរឿងរ៉ាវខាងលើ យើងអាចស្វែងយល់បានថា ទំនួលខុសត្រូវនៅក្នុងគ្រួសា រពិតជាសំខាន់ខ្លាំងណាស់ ជាពិសេសសម្រាប់ក្មេងៗ ការដែលខ្វះភាពកក់ក្តៅ និងការថែទាំពីគ្រួសារ នឹងអាចជះឥទ្ធិពលទៅលើសុខភាពផ្លូវចិត្តរបស់កុមារនៅថ្ងៃខាងមុខ។

ទោះបីជាយ៉ាងណាក៏ដោយ អំពើមនុស្សឃាតក៏មិនត្រូវកើតមាននោះដែរ គឺមិនអាចកើតព្រោះហេតុផលណាក៏ដោយ។

នៅក្នុងសង្គមមួយ គឺតែងតែមានមនុស្សល្អ និងអាក្រក់ដែលមិនបានបែកចែកភេទឡើយ ដូចនេះ គ្រប់កាលៈទេសៈ យើងគ្រប់គ្នាគឺត្រូវចេញតាំងស្មារតី និងប្រយ័ត្នការពារខ្លួនជានិច្ច។

តែទោះជាយ៉ាងណាក៏ដោយ ព្រៃរឿងសង្ឃឹមថា រឿងព្រៃផ្សៃបែបនេះ នឹងមិនកើតមានឡើងក្នុងសង្គមយើងឡើយ។

សូមស្តាប់ដោយត្រិះរិះពិចារណា!

យើងនិងជួបគ្នាម្តងទៀត ក្នុង CamID Podcast ក្រោយ។ សម្រាប់ពេលនេះ សុបិនល្អ និងរាត្រីសួស្តី។

Links and Resources

https://criminalminds.fandom.com/

https://murderpedia.org/

https://www.thoughtco.com/